ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ [illegible]

# ប្រកាស

## ស្តីពី

## ការប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការសម្រាប់ការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងការទូទាត់ជារូបិយបណ្ណបរទេស

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញសេចក្តីណែនាំលេខ ០១៩ សហវ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការផ្ទេរប្រាក់ដុល្លារអាមេរិកពីរតនាគាររាជធានី ខេត្ត មករតនាគារកណ្តាល
- បានឃើញសេចក្តីជូនដំណឹងលេខ ធ១៣.០២២.៧៨៨ សជណ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២ ស្តីពីការបន្ថែមពេលវេលាចេញផ្សាយអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-គោលបំណង**

ប្រកាសនេះ មានគោលបំណងកំណត់ការប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការ ដើម្បីធានានូវតម្លាភាព និងប្រសិទ្ធភាពក្នុងការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងការទូទាត់ចំណាយជារូបិយបណ្ណបរទេស។

**ប្រការ ២.-វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងការទូទាត់ចំណាយជារូបិយបណ្ណបរទេស។

**ប្រការ ៣.-អត្រាប្តូរប្រាក់ផ្លូវការសម្រាប់ប្រមូលចំណូលសារពើពន្ធ**

**ក-ចំណូលសារពើពន្ធលើការនាំចូល-នាំចេញ÷** ត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ ដែលចេញដោយធនាគារជាតិនៃកម្ពុជាសម្រាប់ចុះបញ្ជិកាប្រតិវេទន៍គយ។ ក្នុងករណីនៅថ្ងៃឈប់សម្រាក ឬ មុនម៉ោងដែលធនាគារជាតិនៃកម្ពុជា មិនទាន់បានចេញផ្សាយអត្រាប្តូរប្រាក់ផ្លូវការ ត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាដែលបានចេញផ្សាយមុនមួយថ្ងៃនៃថ្ងៃឈប់សម្រាក។

**ខ-ចំណូលសារពើពន្ធក្នុងស្រុក ត្រូវអនុវត្តដូចខាងក្រោម÷**

**១.អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ**

អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ ដែលចេញដោយធនាគារជាតិនៃកម្ពុជា សម្រាប់រំលេចប្រាក់រៀលលើតម្លៃសរុបក្នុងវិក្កយបត្រ។ ក្នុងករណីការផ្គត់ផ្គង់ត្រូវធ្វើឡើងនៅថ្ងៃឈប់សម្រាក ឬ មុនម៉ោងដែលធនាគារជាតិនៃកម្ពុជា មិនទាន់បានចេញផ្សាយអត្រាប្តូរប្រាក់ផ្លូវការ អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ដែលបានចេញផ្សាយមុនមួយថ្ងៃនៃថ្ងៃឈប់សម្រាក។

ចំពោះអ្នកជាប់ពន្ធអនិវាសនជនដែលបានចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញ មិនតម្រូវឱ្យរំលេចប្រាក់រៀលលើតម្លៃសរុបក្នុងវិក្កយបត្រឡើយ។ ដោយឡែក សម្រាប់គោលដៅរៀបចំលិខិតប្រកាសពន្ធជាប្រាក់រៀល និងគណនាអាករលើតម្លៃបន្ថែមត្រូវបង់ អ្នកជាប់ពន្ធអនិវាសនជនត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការប្រចាំខែ ដូចមានចែងក្នុងចំណុចទី៣ នៃប្រការនេះ។



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

### ២.អត្រាប្តូរប្រាក់ផ្លូវការសម្រាប់ពន្ធលើប្រាក់បៀវត្ស

អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយធនាគារជាតិនៃកម្ពុជា រៀងរាល់ថ្ងៃទី១៥ នៃខែនីមួយៗ សម្រាប់គណនាពន្ធលើប្រាក់បៀវត្ស។ ក្នុងករណី ថ្ងៃទី១៥ នៃខែនីមួយៗ ចំថ្ងៃឈប់សម្រាក ដែលធនាគារជាតិនៃកម្ពុជាមិនបានចេញផ្សាយអត្រាប្តូរប្រាក់ផ្លូវការ អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ដែលបានចេញផ្សាយមុនមួយថ្ងៃនៃថ្ងៃឈប់សម្រាក។

### ៣.អត្រាប្តូរប្រាក់ផ្លូវការប្រចាំខែ

អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃចុងក្រោយនៃខែនីមួយៗ សម្រាប់គណនាពន្ធត្រូវបង់ប្រចាំខែ ចំពោះការផ្គត់ផ្គង់ដោយអ្នកជាប់ពន្ធអនិវាសនជនដែលបានចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញ ឬ ប្រតិបត្តិការទាំងឡាយណា ដែលមិនមានរំលេចប្រាក់រៀលលើវិក្កយបត្រដូចជា ប្រតិបត្តិការដែលទទួលការផ្គត់ផ្គង់ពីបុគ្គលមិនស្ថិតក្នុងរបបស្វ័យប្រកាស ឬ ពីអនិវាសនជន ជាដើម។

### ៤.អត្រាប្តូរប្រាក់ផ្លូវការប្រចាំឆ្នាំ

អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃចុងក្រោយនៃខែធ្នូ នៃឆ្នាំនីមួយៗ សម្រាប់រៀបចំលិខិតប្រកាសពន្ធប្រចាំឆ្នាំ និងគណនាពន្ធត្រូវបង់ប្រចាំឆ្នាំ។

## ប្រការ ៤.-អត្រាប្តូរប្រាក់ផ្លូវការសម្រាប់ប្រមូលចំណូលមិនមែនសារពើពន្ធ

នៅថ្នាក់កណ្តាល ការបង់ចំណូលមិនមែនសារពើពន្ធជារូបិយបណ្ណបរទេស (ប្រាក់ដុល្លារអាមេរិក) ត្រូវបង់ចូលគណនីទោលរតនាគារជាប្រាក់ដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា ឬ គណនីចរន្តរបស់អគ្គនាយកដ្ឋានរតនាគារជាតិនៅធនាគារពាណិជ្ជដៃគូ។ រតនាគារថ្នាក់កណ្តាល ត្រូវកត់ត្រាដោយគិតទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា និងអមដោយប្រាក់ដុល្លារអាមេរិក (ក្រោយពីបានទទួលប្រកាសឥណទាន ឬ របាយការណ៍ធនាគារ)។

នៅថ្នាក់រាជធានី ខេត្ត ការបង់ចំណូលមិនមែនសារពើពន្ធជារូបិយបណ្ណបរទេស (ប្រាក់ដុល្លារអាមេរិក) ត្រូវបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ។ រតនាគាររាជធានី ខេត្ត ត្រូវកត់ត្រាដោយគិតទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា និងអមដោយប្រាក់ដុល្លារអាមេរិក (ក្រោយពីបានទទួលប្រកាសឥណទាន ឬ របាយការណ៍ធនាគារ)។

## ប្រការ ៥.-អត្រាប្តូរប្រាក់ផ្លូវការសម្រាប់ការទូទាត់ជារូបិយបណ្ណបរទេស

អាណត្តិបើកប្រាក់ ឬ លិខិតបុរេប្រទានជាប្រាក់រៀល ត្រូវទូទាត់ជាប្រាក់រៀល ហើយអាណត្តិបើកប្រាក់ ឬ លិខិតបុរេប្រទានជាប្រាក់ដុល្លារអាមេរិក ត្រូវទូទាត់ជាប្រាក់ដុល្លារអាមេរិក ដែលបានកំណត់។ ក្នុងករណីចាំបាច់ អត្ថគាហកអាចស្នើសុំការទូទាត់ខុសពីរូបិយបណ្ណដើម ដែលបានកំណត់នៅក្នុងអាណត្តិបើកប្រាក់ ឬ លិខិតបុរេប្រទាន ដោយធនាគារជាតិនៃកម្ពុជាជាអ្នកកំណត់អត្រាប្តូរប្រាក់។

ក្នុងករណីការបោះផ្សាយអាណត្តិទូទាត់ជារូបិយបណ្ណផ្សេងក្រៅពីប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក នោះធនាគារជាតិនៃកម្ពុជាជាអ្នកកំណត់អត្រាប្តូរប្រាក់។

ការបោះផ្សាយអាណត្តិបើកប្រាក់ជារូបិយបណ្ណបរទេស ដែលមានគោលការណ៍ធានាចំណាយ ត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញលិខិតគោលការណ៍ធានាចំណាយ។

ការបោះផ្សាយអាណត្តិបើកប្រាក់ជារូបិយបណ្ណបរទេស ដែលពុំមានគោលការណ៍ធានាចំណាយ ត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃដែលបោះផ្សាយអាណត្តិបើកប្រាក់។

លម្អៀងរវាងចំនួនទឹកប្រាក់ ដែលបានកត់ត្រាជាចំណាយថវិកា និងចំនួនទឹកប្រាក់ដែលបានទូទាត់ ចាត់ទុកជាចំណេញ ឬ ខាតពីអត្រាប្តូរប្រាក់។ ចំនួនទឹកប្រាក់លម្អៀងត្រូវបានកត់ត្រាដោយពុំចាំបាច់មានសលាកប័ត្របង់ចំណូលថវិកា ឬ អាណត្តិបើកប្រាក់។

ចំពោះការបើកផ្តល់បុរេប្រទានជាប្រាក់ដុល្លារអាមេរិក និងការបោះផ្សាយអាណត្តិនីយ័តកម្ម ត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃដែលគណនេយ្យករសាធារណៈបានធ្វើការបើកផ្តល់សាច់ប្រាក់។

**ប្រការ ៦.-អត្រាប្តូរប្រាក់ផ្លូវការសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល**

ចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដោយឡែក ដែលមានជាធរមាន។

**ប្រការ ៧.-និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋាន ឬ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

ថ្ងៃ[illegible]ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- សាលារាជធានី ខេត្ត
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel